ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
CAMBODIAN NATIONAL COUNCIL
FOR CHILDREN

ភ្នំពេញ ថ្ងៃទី ១៨ ខែ ក្ក ឆ្នាំ២០០០

លេខ..139.......ក.ជ.ក.ក

# សេចក្តីសំរេច
## ស្តីពី
## ការបង្កើតអនុគណៈកម្មការ ប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៥៦ អនក្របក ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- បានឃើញសេចក្តីប្រកាស លេខ ០១ ចុះថ្ងៃទី ០៦ ខែមេសា ឆ្នាំ ២០០០ ស្តីពីវិធានការចាត់តាំងអនុវត្ត ផែនការជាតិ ៥ឆ្នាំ ប្រឆាំងការជួញដូរ និង កេងប្រវ័ញ្ចផ្លូវភេទលើកុមារ ។

## សំរេច

**ប្រការ ១** : បង្កើតអនុគណៈកម្មការប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្នុងគោលបំណង សំរបសំរួល ពិនិត្យតាមដាន ការអនុវត្តន៍ផែនការជាតិ៥ឆ្នាំប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និង កម្មវិធីផ្សេងៗទៀតដែលពាក់ព័ន្ធ ។ ធ្វើសកម្មភាពជាក់ស្តែងផ្អែកតាមផែនការជាតិ និង ធ្វើការវាយតំលៃលើស្ថានការណ៍ នៃការចាប់ពង្រត់ ការជួញដូរ និង ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ។

ប្រការ ២ : សមាសភាពអនុគណៈកម្មការប្រឆាំងការជួញដូរ និង កេងប្រវ័ញ្ចផ្លូវភេទលើកុមារ មាន :

១- ឯកឧត្តម អនុប្រធាន ក.ជ.ក.ក តំណាងក្រសួងមហាផ្ទៃ ជា ប្រធាន

២- លោកជំទាវអនុប្រធាន ក.ជ.ក.ក តំណាងក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ជា អនុប្រធាន

៣- ឯកឧត្តម អនុរដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ ជា អនុប្រធាន

៤- ឯកឧត្តមអនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ជា អនុប្រធាន

៥- ឯកឧត្តមអនុប្រធាន ក.ជ.ក.ក តំណាងក្រសួងសុខាភិបាល ជា អនុប្រធាន

៦- សមាជិក ក.ជ.ក.ក តំណាងក្រសួងទេសចរណ៍ ជា សមាជិក

៧- សមាជិក ក.ជ.ក.ក តំណាងក្រសួងការពារជាតិ ជា សមាជិក

៨- មន្ត្រីក្រសួងយុត្តិធម៌ ជា សមាជិក

៩- មន្ត្រីក្រសួងមហាផ្ទៃ ជា សមាជិក

១០- មន្ត្រីក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ជា សមាជិក

១១- មន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ជា សមាជិក

១២- សមាជិក ក.ជ.ក.កតំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជា សមាជិក

១៣- សមាជិក ក.ជ.ក.ក តំណាងក្រសួងអភិវឌ្ឍន៍ជនបទ ជា សមាជិក

១៤- មន្ត្រីក្រសួងអប់រំយុវជន និង កីឡា ជា សមាជិក

ប្រការ ៣ : អនុគណៈកម្មការ ប្រឆាំងការជួញដូរ និង កេងប្រវ័ញ្ចផ្លូវភេទលើកុមារ មានភារកិច្ចដូចតទៅ :

- ផ្សព្វផ្សាយដល់សាធារណៈជន និងស្ថាប័ននានាអោយមានការយល់ដឹងអំពីបញ្ហា ជួញដូរ និង កេងប្រវ័ញ្ចផ្លូវភេទលើកុមារ ផែនការជាតិ៥ឆ្នាំ ប្រឆាំងការជួញដូរ និង កេងប្រវ័ញ្ចផ្លូវភេទ លើកុមារ ច្បាប់ សារាចរ សេចក្តីសំរេច បទបញ្ញត្តិផ្សេងៗ ដែលពាក់ព័ន្ធ និង ធ្វើការទាក់ ទាញមតិគាំទ្រ ។
- ជំរុញ និង សំរបសំរួលការអនុវត្តន៍ផែនការជាតិ ៥ឆ្នាំ ប្រឆាំងការជួញដូរ និង កេងប្រវ័ញ្ចផ្លូវភេទលើកុមារ នៅថ្នាក់កណ្តាល ថ្នាក់ ខេត្ត - ក្រុង ។
- សហប្រតិបត្តិការជាមួយស្ថាប័នរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ និង ប្រទេសដែលពាក់ព័ន្ធ ។
- សិក្សាស្រាវជ្រាវ និង ប្រមូលពត៌មានទាំងឡាយដែលទាក់ទងទៅនឹងបញ្ហាជួញដូរ និង កេង ប្រវ័ញ្ចផ្លូវភេទលើកុមារ ។
- ពិនិត្យតាមដាន វាយតំលៃ លើកម្មវិធី សកម្មភាពទាំងឡាយដែលពាក់ព័ន្ធ ទៅនឹងការជួញដូរ និង កេង

ប្រវិញ្ញផ្លូវភេទលើកុមារ ព្រមទាំងធ្វើរបាយការណ៍ ផ្តល់អនុសាសន៍អំពីស្ថានភាព និង លទ្ធផលនៃការអនុវត្តន៍ផែនការជាតិ ជូន ក.ជ.ក.ក និង រាជរដ្ឋាភិបាល ។

- ពិនិត្យតាមដាន ករណីជាក់លាក់នៃការជួញដូរ និង កេងប្រវ័ញ្ចផ្លូវភេទលើកុមារ ការងារចាត់ចែងរបស់អាជ្ញាធរ និងផ្តល់មតិយោបល់ជូនដល់អាជ្ញាធរមានសមត្ថកិច្ច ។

<u>ប្រការ ៤</u> : តំណាងភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ និង បណ្តា ឯកត្តជនដែលចាប់អារម្មណ៍អាចចូលរួមប្រជុំជាសមាជិកសង្កេតការណ៍តាមការអញ្ជើញរបស់អនុគណៈកម្មការ ។

<u>ប្រការ ៥</u> : អនុគណៈកម្មការប្រឆាំងការជួញដូរ និង កេងប្រវ័ញ្ចផ្លូវភេទលើកុមារត្រូវមានបទបញ្ជាផ្ទៃ ក្នុងដោយឡែករបស់ខ្លួន និង មានការិយាល័យមួយចំណុះអោយអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ ក.ជ.ក.ក ។ ចំពោះតួនាទី និង ភារកិច្ចរបស់ការិយាល័យត្រូវកំណត់ដោយ អនុគណៈកម្មការប្រឆាំងការជួញដូរ និង កេងប្រវ័ញ្ចផ្លូវភេទលើកុមារ ។

<u>ប្រការ ៦</u> : សេចក្តីសំរេចនេះ មានប្រសិទ្ធភាពអនុវត្តន៍ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ច. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

ប្រធាន

អ៊ិត សំហេង

<u>ចំលងជូន</u> :

- ព្រឹទ្ធសភា
- រដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរដែនដីគ្រប់ខេត្ត-ក្រុង
- កងរាជអាវុធហត្ថលើផ្ទៃប្រទេស
- អង្គការជាតិ អន្តរជាតិ ដែលពាក់ព័ន្ធនឹងកុមារ
  "ដើម្បីជូនជ្រាបជាពត៌មាន"
- ដូចប្រការ ២ "ដើម្បីអនុវត្ត"
- រាជកិច្ច